គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា
Committee for Free and Fair Elections in Cambodia
ខុមហ្វ្រែល COMFREL

Vision : A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

ទស្សនវិស័យ ៖ ដើម្បីឲ្យការបោះឆ្នោតមានលក្ខណៈប្រជាធិបតេយ្យ ដែលផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋ។

ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១១

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## លទ្ធផលសិក្ខាសាលាសម្លេងម្ចាស់ឆ្នោត ឃុំកិចុង ស្រុកបរកែវ ខេត្តរតនៈគិរី

ដោយមានការគាំទ្រពីគណៈកម្មាធិការខុមហ្វ្រែល សហការជាមួយនឹងសមាគមអាដហុក សហគមន៍ព្រៃឈើ បានរៀបចំសិក្ខាសាលាសម្លេងម្ចាស់ឆ្នោតមួយស្តីពី **ការកំណត់តម្រូវការជាអាទិភាព ក្នុងឃុំសង្កាត់ជាច់ស្រយាល** ដែលធ្វើឡើងនៅ **ឃុំកិចុង ស្រុកបរកែវ ខេត្តរតនគិរី** កាលពីថ្ងៃទី២៧ ខែ មិថុនា ឆ្នាំ២០១១។ មានអ្នកមានសិទ្ធិបោះឆ្នោតប្រមាណ ៦៥ នាក់ (២៦% ជាស្ត្រី ៧០%ជនជាតិដើមទំពូន និងចារាយ) មកពីគ្រប់ភូមិក្នុងឃុំ ដែលរួមមានតំណាងសហគមន៍ តំណាងគណបក្សនយោបាយប្រចាំឃុំ និងជាសមាជិកក្រុមប្រឹក្សាឃុំ អាជ្ញាធរភូមិ អង្គការមូលដ្ឋាន និងប្រជាពលរដ្ឋនៅក្នុងឃុំបានចូលរួមពិភាក្សានៅក្នុងសិក្ខាសាលានេះ។

ប្រជាពលរដ្ឋដែលចូលរួមសិក្ខាសាលាស្ទើរតែ១០០% បានបោះឆ្នោតគាំទ្រតម្រូវការជាអាទិភាពទាំង ៥ នៅក្នុងឃុំ ដែលស្នើឱ្យក្រុមប្រឹក្សាឃុំបច្ចុប្បន្ន យកចិត្តទុកដាក់ដោះស្រាយ និង/ឬគណបក្សនយោបាយទទួលយកដើម្បីដាក់បញ្ចូលទៅក្នុងកម្មវិធីនយោបាយរបស់ខ្លួនក្នុងការបោះឆ្នោតឃុំ-សង្កាត់ខាងមុខ។

| តម្រូវការជាអាទិភាព ទាំង ៥ ក្នុង ឃុំកចុង ស្រុកបរកែវ ខេត្តរតនៈគិរី |
|---|
| **១ - ការសាងសង់ប៉ុស្តិ៍សុខភាព និងធុងចម្រោះទឹកស្អាត**<br>o សុំប៉ុស្តិ៍សុខភាពចំនួន ៩ប៉ុស្តិ៍ នៅ ៩ភូមិ ក្នុងទូទាំងឃុំ ដោយសាងសង់ពីបេតុង និងមានបំពាក់សំភារៈបរិក្ខាពេទ្យឱ្យបានគ្រប់គ្រាន់ និងគ្រូពេទ្យដែលមានជំនាញគ្រប់គ្រាន់ប្រចាំការនៅតាមប៉ុស្តិ៍នីមួយៗ ដោយការសាងសង់តាមស្តង់ដា សុំកសាងឱ្យរួចរាល់នៅក្នុងឆ្នាំ ២០១២។<br>o សុំធុងចម្រោះទឹកស្អាតគ្រប់ភូមិទាំង៩ភូមិ ចំនួន ៨៣៩ធុង ក្នុង ៨៣៩គ្រួសារ ដោយមួយ គ្រួសារមួយធុង សូមចាប់ផ្តើមពីឆ្នាំ២០១១ និងចប់សព្វគ្រប់ឆ្នាំ២០១២។<br>o សុំថ្នាំសំលាប់ដង្កូវទឹកចំនួន៩ភូមិ ស្មើនឹង ៨៣៩គ្រួសារ អោយបាននៅឆ្នាំ ២០១១ ដល់២០១២ ។ |
| |

ទីស្នាក់ការកណ្តាល ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Central Office : #138, Street. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.
P.O. Box 1145, Phone : (855) 23 884 150 Fax: (855) 23 885 745 E-mail : comfrel@online.com.kh Website: www.comfrel.org

**២ - ការសាងសង់សាលារៀន**

- សុំសាលារៀនបឋមសិក្សា ១ខ្នង មាន ៦បន្ទប់ សាងសង់តាមស្តង់ដា សំរាប់៥ភូមិ គឺ**ភូមិលើឃ្វូន ភូមិជ្រុង ភូមិទៀន ភូមិប៉ាអរ ភូមិលើហ័ន្ត** សាងសង់នៅចំនុច**ភូមិប៉ាអរ** និងសាងសង់បន្ទប់ទឹកចំនួន ១០បន្ទប់ ទឹក១ និងបង្គន់១ សំរាប់ប្រុស និងស្រី ដាច់ដោយឡែក សាងសង់ពីបេតុង និងបំពាក់សំភារៈ សិក្សាមានតុ កៅអី ក្តាខៀន តុគ្រូ សូមឱ្យចាប់ផ្តើមអនុវត្តន៍នៅឆ្នាំ២០១២ និង បញ្ចប់ឆ្នាំ២០១៣ ។
- សុំអំពូលភ្លើងសូឡែ ៦គ្រឿង ដែលមួយគ្រឿងមានអំពូល ២ នៅ**ភូមិប៉ាអរ ភូមិជ្រុង ភូមិលើឃ្វូន** សំរាប់សិស្សរៀន អក្ខរកម្មនៅពេលយប់ សុំឱ្យបាននៅចុងឆ្នាំ២០១១។

**៣ - ការសាងសង់បង្គន់អនាម័យ**

- សុំសាងសង់បង្គន់អនាម័យចំនួន៥០ ដែលមានអាងទឹក១ នៅក្នុងបង្គន់១ ធ្វើពីបេតុង ទំហំ២ម៉ែត្រ គុណនឹង៣ម៉ែត្រ ក្នុងមួយភូមិចំនួន ១០បង្គន់ សម្រាប់ ៥ភូមិ គឺ **ភូមិប៉ាអរ ភូមិជ្រុង ភូមិលើឃ្វូន ភូមិទៀង ភូមិលើហ័ន្ត** សាងសង់ឱ្យរួចរាល់នៅឆ្នាំ២០១៣។

**៤ - ការស្នើសុំកូនឈើ និងគ្រូពេទ្យសត្វ**

- សុំកូនឈើហូបផ្លែ(សាវម៉ាវ ធូរ៉េន ដូងស្វាយ)ចំនួន ១០០០ដើម សំរាប់១ភូមិ ទាំងអស់ ៩ភូមិ សរុប ៩០០០ដើម អោយបានឆ្នាំ២០១២។
- សុំគ្រូពេទ្យសត្វអោយបានម្នាក់សំរាប់មួយភូមិ ប្រចាំការ និងមានថ្នាំការពារគ្រប់ប្រភេទនៅពេល សត្វឈឺ សុំឱ្យបាននៅចុងឆ្នាំ២០១១។

**៥ - ការជីកអណ្តូងទឹកស្អាត**

- សុំអណ្តូងទឹកខួងចំនួន១៨ សំរាប់៩ភូមិ ហើយមួយភូមិចំនួន២អណ្តូង ដែលមានជម្រៅ៥៣ម៉ែត្រ ដោយបំពាក់ម៉ូទ័រ និងម៉ាស៊ីនភ្លើងចំនួន១គ្រឿង សំរាប់មួយអណ្តូងដែលអាច អូសម៉ូទ័របាន ឱ្យបាននៅចុងឆ្នាំ២០១១។

មុនពេលបញ្ចប់សិក្ខាសាលា មានកម្មវិធីប្រគល់របាយការណ៍ ពីតម្រូវការជាអាទិភាពដល់អ្នកដឹកនាំគណបក្សនយោបាយប្រចាំឃុំ និងក្រុមប្រឹក្សាឃុំ។

**លោក រចំ ភើន** តំណាងគណបក្សសមរង្ស៊ី និងជាជំទប់ទី២ មានបានប្រសាសន៍ផ្តាំផ្ញើថា«សុំអោយប្រជាពលរដ្ឋយើងទាំងអស់ដែលជាម្ចាស់ឆ្នោត កត់ត្រាទុកនូវអ្វីដែលយើងបានរកឃើញនៅពេលសិក្ខាសាលានេះ ដើម្បីជម្រុញអោយមានការអភិវឌ្ឍន៍ទាំងអស់គ្នា មិនថាគណបក្សនេះឬ គណបក្សនោះឡើយ »។

**លោក ភ្លាស ទៀន** តំណាងគណបក្សហ្វ៊ុនស៊ិនប៉ិច បានមានប្រសាសន៍ថា «ប្រជាពលរដ្ឋទាំងអស់គ្នាឃើញស្រាប់ហើយ ច្បាប់ប្រជាធិបតេយ្យ យកពស្ត្រជាធំពលរដ្ឋដែលជាម្ចាស់ឆ្នោត ហ៊ានជ្រើសរើស អាទិភាពរបស់ខ្លួន អោយអ្នកតំណាងធ្វើតាម និងមានការផ្លាស់ប្តូរ ចូលរួមឃ្លាំមើលតាមដាន រាល់ការងារអភិវឌ្ឍន៍ទាំងអស់របស់អ្នកតំណាងរបស់ខ្លួន។»

សិក្ខាសាលានេះ មានគោលបំណង ឱ្យម្ចាស់ឆ្នោតនៅតំបន់ដាច់ស្រយាលទទួលបាន៖

១. ការយល់ដឹងអំពីសិទ្ធិ តួនាទី និងកាតព្វកិច្ចរបស់ម្ចាស់ឆ្នោត ក្នុងការស្វែងយល់ពីតម្រូវការជាអាទិភាពក្នុងការអភិវឌ្ឍន៍នូវមូលដ្ឋាន។
២. ផ្តល់ឱកាសឱ្យម្ចាស់ឆ្នោតចូលរួម ជជែកពិភាក្សា ដើម្បីកំណត់តម្រូវការអាទិភាពក្នុងឃុំ សង្កាត់របស់ខ្លួន។
៣. តម្រូវការជាអាទិភាពក្នុងឃុំ សង្កាត់ ដាច់ស្រយាល នឹងត្រូវបានចងក្រងជា របាយការណ៍ដែលអាចឱ្យសិក្ខាកាមងាយចងចាំដើម្បីចូលរួមតាមដាន ជម្រុញការអនុវត្តន៍របស់ក្រុមប្រឹក្សា ឃុំ សង្កាត់ និងការដាក់បញ្ចូលតម្រូវការក្នុងកម្មវិធីនយោបាយរបស់គណបក្សសម្រាប់ការបោះឆ្នោតឃុំ សង្កាត់ ឆ្នាំ ២០១២។

សិក្ខាសាលានេះក៏បានទទួលការឧបត្ថម្ភមូលនិធិពីសហភាពអឺរ៉ុប (EU), OXFAM NOVIB, NPA និង Forum Syd

[1]**សម្រាប់ព័ត៏មានបន្ថែមសូមទំនាក់ទំនង ៖**

១-លោក **ម្លូច ឿត** (មន្ត្រីផ្នែកបណ្តាញ និងវេទិកា)

ទូរស័ព្ទលេខ ៖ **០១២ ៤៧១ ៣២៦**

២-អ្នកស្រី **ហេង សុគន្ធា** (ជំនួយការផ្នែកបណ្តាញ និងវេទិកា)

ទូរស័ព្ទលេខ ៖ **០១៧ ៥៨៣ ៨៦៩**

[1] No 022